## ក្រសួងអប់រំ យុវជន និងកីឡា




# ក្លឹបអាស៊ាន

២០២៣

ឯកសារបោះពុម្ពនេះ ត្រូវបានរៀបចំចងក្រងឡើង ក្រោមគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ (USESDP2) របស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រោមកិច្ចសហការជាមួយអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា ដើម្បីចងក្រងជាឯកសារនវានុវត្តក្នុងការបង្កើត និងការដឹកនាំក្លឹប។

***រូបភាពក្របសៀវភៅ:*** រចនាដោយលោក អឿ សារីន អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា

© ក្រសួង អ.យ.ក ២០២៣

# មាតិកា


**បុព្វកថា** ..... III

**១. សេចក្ដីផ្ដើម** ..... ១

**២. លទ្ធផលសិក្សា** ..... ១

២.១. វត្ថុបំណង ..... ១

២.២. លទ្ធផល ..... ២

**៣. សម្ភារៈ** ..... ២

**៤. ដំណើរការអនុវត្តសកម្មភាព** ..... ២

៤.១. គោលការណ៍រៀបចំ ..... ២

៤.១.១. ការស្ម័គ្រចិត្ត ..... ២

៤.១.២. ទំហំ ..... ៣

៤.១.៣. កម្រិតថ្នាក់គោលដៅ ..... ៣

៤.១.៤. ការវាយតម្លៃចំណាប់អារម្មណ៍សិស្ស និងការតម្រង់ទិស ..... ៣

៤.១.៥. ការបែងចែកតារកិច្ច ..... ៤

៤.១.៦. ការកំណត់ផែនការ ..... ៤

៤.១.៧. ការកំណត់ធនធាន ..... ៥

៤.២. សកម្មភាពស្នើឡើង ..... ៦

៤.២.១. ការយល់ដឹងពីអាស៊ាន ..... ៦

៤.២.២. ការស្រាវជ្រាវពីរដ្ឋសមាជិកអាស៊ាន ..... ៩

៤.២.៣. ការតាំងពិព័រណ៍ស្នាដៃក្នុងបណ្ណាល័យ ..... ១៣

៤.២.៤. ការបង្កើតប្រអប់សំណុំឯកសារ ឬខិត្តប័ណ្ណអាស៊ានក្នុងបណ្ណាល័យ ..... ១៥

៤.២.៥. ការពិភាក្សា និងការជជែកដេញដោល ..... ១៦

៤.២.៦. ទស្សនកិច្ចសិក្សា ..... ១៨

៤.២.៧. ការប្រជុំឆ្លុះបញ្ចាំងដើម្បីវាយតម្លៃសកម្មភាពប្រចាំឆ្នាំ ..... ១៨

**ឧបសម្ព័ន្ធទី១៖ ការវាយតម្លៃចំណាប់អារម្មណ៍សិស្ស** ..... ១៩

**ឧបសម្ព័ន្ធទី២៖ ការបែងចែកភារកិច្ច** ..... ២០

**ឧបសម្ព័ន្ធទី៣៖ ការកំណត់ផែនការ** ..... ២១

**ឧបសម្ព័ន្ធទី៤៖ ការកំណត់ធនធាន** ..... ២២

# មុខកថា

ការអភិវឌ្ឍធនធានមនុស្ស គឺជាកត្តាសំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ការអប់រំបានបណ្តុះនូវមូលធនមនុស្សប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងមនសិការវិជ្ជាជីវៈសម្រាប់សង្គមជាតិ។ ក្នុងបរិការណ៍នេះ ក្រសួងអប់រំ យុវជន និងកីឡា បានកសាងឯកសារក្លឹបសិក្សាបន្ថែមសម្រាប់ប្រើប្រាស់នៅតាមគ្រឹះស្ថានមធ្យមសិក្សា។

ឯកសារនេះ នឹងផ្តល់នូវទិដ្ឋភាពថ្មីៗ ដល់សិស្សានុសិស្សទាំងអស់ដែលត្រូវការសិក្សាបន្ថែមក្រៅពីការរៀននៅក្នុងថ្នាក់រៀន។ ការបង្កើតក្លឹបសិក្សា គឺជាការងារស្ម័គ្រចិត្ត ដែលនឹងត្រូវជ្រើសរើសយកទៅអនុវត្តតាមតម្រូវការជាក់ស្តែងរបស់គ្រឹះស្ថានមធ្យមសិក្សា។ ការណ៍នេះ សិស្សានុសិស្ស នឹងទទួលបានឱកាសអភិវឌ្ឍគុណសម្បទាផ្ទាល់ខ្លួនបន្ថែមទៀត តាមរយៈការចូលរួមសកម្មភាពក្លឹបសិក្សា ណាមួយដែលពួកគេចាប់អារម្មណ៍។ ការផ្តល់សេវាអប់រំមានលក្ខណៈសម្បូរបែបនេះ នឹងមានផលជះវិជ្ជមាន ដល់ការផ្លាស់ប្តូរឥរិយាបថ និងអាកប្បកិរិយារបស់សិស្សានុសិស្ស ឱ្យមានលទ្ធភាពសម្របខ្លួនទៅនឹងការវិវត្តជឿនលឿននៃសង្គមជាតិក្នុងយុគសម័យឌីជីថល។

ការបង្កើតក្លឹបសិក្សា ទាមទារឱ្យមានយន្តការណែនាំច្បាស់លាស់អំពី តួនាទី និងភារកិច្ច សម្រាប់គ្រូដឹកនាំ និងសមាជិកក្លឹប តម្រូវការធនធានគាំទ្រ លំនាំសកម្មភាពត្រូវអនុវត្ត និងប្រធានបទដែលត្រូវសិក្សាក្នុងអំឡុងពេលដំណើរការក្លឹប។ ឯកសារនេះ បានផ្តល់នូវមូលដ្ឋានច្បាស់លាស់ដល់គណៈគ្រប់គ្រងសាលារៀន និងលោកគ្រូអ្នកគ្រូ ក្នុងការចាត់ចែង រៀបចំ បង្កើតឱ្យមានក្លឹបសិក្សានៅក្នុងគ្រឹះស្ថានសិក្សារបស់ខ្លួន ដើម្បីផ្តល់ឱកាសដល់សិស្ស ដែលមានចំណាប់អារម្មណ៍ចូលរួមក្នុងសកម្មភាពក្លឹបណាមួយដោយការស្ម័គ្រចិត្ត។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមយ៉ាងមុតមាំថា គ្រឹះស្ថានមធ្យមសិក្សា នឹងប្រើប្រាស់ឯកសារនេះជាមូលដ្ឋានក្នុងការបង្កើតក្លឹបសិក្សា ដោយបត់បែនតាមស្ថានភាពជាក់ស្តែងរបស់សាលារៀន ប្រកបដោយប្រសិទ្ធភាព សំដៅរួមចំណែកកសាង និងអភិវឌ្ឍធនធានមនុស្សនៅកម្ពុជាឱ្យកាន់តែល្អប្រសើរ។

ថ្ងៃ អង្គារ ១ រោច ខែ ផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០២៣

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

## ១. សេចក្តីផ្តើម

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បណ្តាប្រទេសនៃតំបន់អាស៊ីអាគ្នេយ៍ បានបង្កើននូវសក្តានុពលខ្លាំងក្លាក្នុងការអភិវឌ្ឍឱ្យមានកំណើនសេដ្ឋកិច្ចក្នុងតំបន់ និងលើឆាកអន្តរជាតិ។ ការស្វែងយល់ពីបញ្ហាអាស៊ានមានសារៈសំខាន់ក្នុងការដោះស្រាយបញ្ហាថ្នាក់តំបន់ និងអន្តរជាតិនាពេលអនាគត។ អាស៊ានតំណាងឱ្យភាពចម្រុះអរិយធម៌ វប្បធម៌ និងក្រុមជាតិពន្ធុ។ សហគមន៍អាស៊ានប្រកាន់យកនូវភាពផ្សេងៗគ្នានៃជំនឿ ភូមិសាស្ត្រ សេដ្ឋកិច្ច នយោបាយ និងសាវតាប្រវត្តិសាស្ត្រ ក៏ដូចជាការចែករំលែកនូវលក្ខណៈរួមផងដែរ។ ឯកសារនេះត្រូវបានកសាងឡើង ដើម្បីជួយសម្រួលដល់សាលាមធ្យមសិក្សា ក្នុងការផ្តល់ឱកាសបន្ថែមសម្រាប់សិស្សបានស្វែងយល់ពីសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) រចនាសម្ព័ន្ធ ទំនៀមទំលាប់ អរិយធម៌ វប្បធម៌ និងប្រពៃណីរបស់ជាតិសាសន៍ៗនៃសមាជិកអាស៊ានទាំងអស់ និងបានលើកកម្ពស់ការអភិវឌ្ឍគុណសម្បទារបស់សិស្សឱ្យក្លាយជាធនធាននៃប្រទេសកម្ពុជា និងតំបន់ក្នុងពេលអនាគត។

ការអនុវត្តសកម្មភាពក្លឹបនេះនឹងធ្វើឡើងក្រៅម៉ោងសិក្សា ស្ថិតក្រោមការដឹកនាំរបស់គ្រូម្នាក់ ឬច្រើននាក់។ សមាជិកភាពដែលចូលរួមបង្កើតក្រុមនេះ គឺជាការស្ម័គ្រចិត្ត។ គោលបំណងក្លឹបអាស៊ាន គឺដើម្បីរៀបចំសកម្មភាពទាំងឡាយតាមរចនាសម្ព័ន្ធ ដែលក្នុងនោះសិស្សត្រូវចូលរួមយ៉ាងសកម្មក្នុងការស្រាវជ្រាវ ការគិត និងការធ្វើបទបង្ហាញពីលទ្ធផលស្រាវជ្រាវរបស់ពួកគេ។

សកម្មភាពទាំងនេះ រួមមានដូចជា ការស្រាវជ្រាវតាមប្រព័ន្ធកុំព្យូទ័រ ការសម្ភាសផ្ទាល់មាត់ រៀបចំក្តារខៀនព័ត៌មានពីរដ្ឋសមាជិកអាស៊ានក្នុងមជ្ឈមណ្ឌលរបស់សាលា (ក្នុងមួយខែត្រូវតាំងបង្ហាញពីព័ត៌មានរបស់រដ្ឋសមាជិកអាស៊ានមួយ) ដោយរៀបចំបញ្ជីឯកសារព័ត៌មានអាស៊ានដែលបានមកពីការធ្វើកម្មសិក្សា។ វាគឺជារឿងសំខាន់សម្រាប់សមានជិកក្លឹប ក្នុងការចែករំលែកបទពិសោធន៍របស់ខ្លួនជាមួយសិស្សដទៃទៀត។ សកម្មភាពដែលបានស្នើនេះ ផ្តល់ឱកាសដល់សិស្ស ក្នុងការចែករំលែកការស្រាវជ្រាវពីសហគមន៍អាស៊ានជាមួយសិស្សដទៃទៀតតាមរយៈការតាំងពិព័រណ៍ និងការធ្វើបទបង្ហាញ។

បច្ចុប្បន្ននេះ ការស្រាវជ្រាវព័ត៌មានតាមប្រព័ន្ធកុំព្យូទ័រ ឬសៀវភៅនានា គួរក្លាយជាទម្លាប់សម្រាប់សិស្ស ដើម្បីជួយដល់ពួកគេក្នុងការសិក្សាប្រចាំថ្ងៃ។ វាផ្តល់ឱកាសដល់សិស្សក្នុងការគិត និងពិភាក្សាជាមួយគ្រូពីអ្វីជារដ្ឋសមាជិកអាស៊ាន និងចំណុចពាក់ព័ន្ធរវាងគ្នានៃប្រជាជនក្នុងតំបន់។

★ ក្លឹបគឺៈ ការប្រមូលផ្តុំនៃមនុស្សមួយក្រុមដោយមានគោលដៅរួម ឬមានចំណង់ចំនូលចិត្តដូចគ្នាដើម្បីធ្វើកិច្ចការរួម និងផលប្រយោជន៍រួមមួយ ។

## ២. លទ្ធផលសិក្សា

### ២.១. វត្ថុបំណង

ផ្អែកលើការពិភាក្សាខាងលើនេះ ក្លឹបអាស៊ានមានវត្ថុបំណងដូចខាងក្រោមៈ

- សិស្សមានឱកាសរៀនបន្ថែមពីសហគមន៍អាស៊ាន ដូចជា នយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌
- សិស្សមានឱកាសចែករំលែកបញ្ហានានា ដែលប៉ះពាល់ដល់ជីវិតរបស់ពួកគេប្រកបដោយគុណភាព

- គ្រូប្រើឯកសារនេះ ដើម្បីជួយសិស្សក្នុងការរៀបចំសកម្មភាពតាមរចនាសម្ព័ន្ធ ដែលធ្វើឱ្យពួកគេអភិវឌ្ឍលើចំណេះដឹង ការត្រិះរិះពិចារណា ការធ្វើបទបង្ហាញ និងការរៀបចំ។

២.២. លទ្ធផល

ដើម្បីសម្រេចវត្ថុបំណងខាងលើ ខាងក្រោមនេះគឺជាសកម្មភាពដែលត្រូវផ្តោតការយកចិត្តទុកដាក់៖

- អភិវឌ្ឍបំណិនត្រិះរិះពិចារណា ការធ្វើបទបង្ហាញ និងការរៀបចំតាមរយៈសកម្មភាពផ្សេងៗ ដែលជួយសិស្សឱ្យកើនឡើងនូវចំណេះដឹងទូទៅ និងការយល់ដឹងពីសហគមន៍អាស៊ាន
- ផ្តល់ឱកាសសម្រេចបាននូវគោលបំណងផ្ទាល់ខ្លួន និងចែករំលែកលទ្ធផលដែលរកឃើញជាមួយសិស្សដទៃទៀតតាមមធ្យោបាយច្នៃប្រតិដ្ឋ។

## ៣. សម្ភារៈ

សម្ភារៈដែលរៀបរាប់ខាងក្រោមគ្រាន់តែជាយោបល់ប៉ុណ្ណោះ ប៉ុន្តែវាអាស្រ័យលើសកម្មភាពសិស្សធ្វើជាក់ស្តែង៖

- សម្ភារៈស្រាវជ្រាវផ្សេងៗ (ឧទាហរណ៍៖ សៀវភៅ ផែនទី ។ល។)
- សម្ភារៈការិយាល័យ ប៊ិច សៀវភៅសរសេរ
- ក្រដាសផ្ទាំងធំ (poster)
- បន្ទប់កុំព្យូទ័រ
- ទូរទស្សន៍
- ប្រាក់ឧបត្ថម្ភគ្រូដឹកនាំ (ប្រសិនបើចាំបាច់)។

## ៤. ដំណើរការអនុវត្តសកម្មភាព

### ៤.១. គោលការណ៍រៀបចំ

ការបង្កើតក្លឹបអាស៊ាន ត្រូវធ្វើឡើងដោយមានគោលការណ៍អនុវត្តសំខាន់ៗមួយចំនួនដូចខាងក្រោម៖

#### ៤.១.១. ការស្ម័គ្រចិត្ត

អ្នកសម្របសម្រួលសាលារៀនត្រូវយល់ថា ការចូលរួមក្នុងក្លឹបអាស៊ាននេះ គឺមិនមែនសម្រាប់មនុស្សគ្រប់គ្នាទេ និងមិនត្រូវបង្ខំសិស្សឱ្យចូលរួមក្នុងក្លឹបនេះដែរ។ សិស្សមានចំណូលចិត្តខុសៗគ្នា ដូចនេះ អ្នកសម្របសម្រួលគួរជួយសម្រួលដល់បញ្ហានេះឱ្យបានសមរម្យស្របតាមបញ្ញត្តិសាលាកុមារមេត្រី។ ឧទាហរណ៍ គ្រូអាចបង្កើតក្លឹបនេះក្នុងពេលតែមួយ ខណៈពេលដែលក្លឹបដទៃទៀតត្រូវបានបង្កើតផងដែរ។ វាមានន័យថាមានគ្រូផ្សេងៗទៀតកំពុងបង្កើតក្លឹបដទៃទៀតដែរ ដូចជាក្លឹបវិទ្យាសាស្ត្រ ឬក្លឹបនិពន្ធជាដើម។ គ្រូគួរទុកពេលឱ្យសិស្សជ្រើសរើសក្លឹបដែលពួកគេចង់ចូលរួមឱ្យបានទូលំទូលាយ និងត្រូវមើលថាតើពួកគេមានពេលវេលា និងចំណូលចិត្តក្នុងការចូលរួមក្លឹបដែរឬទេ។

ដូចគ្នានេះដែរ ថ្នាក់ដឹកនាំក៏មិនត្រូវបង្ខំគ្រូឱ្យរៀបចំក្លឹបអាស៊ាននេះដែរ។ ការពេញចិត្ត និងការចាប់អារម្មណ៍របស់គ្រូ ចំពោះការដឹកនាំក្លឹបអាស៊ានជាប្រការចាំបាច់ក្នុងការឈានទៅដល់ភាពជោគជ័យរបស់ក្លឹប

ជាមួយគ្នានេះដែរ គ្រូស្ម័គ្រចិត្តអាចចំណាយពេលផ្ទាល់ខ្លួនរបស់គាត់ខ្លះៗ ដើម្បីធ្វើផែនការសកម្មភាពជាមួយសិស្ស ដូចជាការចូលរួមប្រជុំក្រៅម៉ោងសិក្សា និងការធ្វើដំណើរទស្សនកិច្ចនានាក្នុងមូលដ្ឋាន។ គណៈកម្មការសាលា ត្រូវពិចារណាលើទម្រង់ការមួយចំនួនទាក់ទងនឹងប្រាក់ឧបត្ថម្ភគ្រូដឹកនាំក្លឹបដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងទម្រង់ថវិកាសកម្មភាពផ្សេងទៀតដូចជា ការបំប៉នសិស្សរៀនយឺត និងកម្មវិធីគេហកិច្ច ជាដើម។

### ៤.១.២. ទំហំ

ក្លឹបអាស៊ាននេះមានភាពងាយស្រួលក្នុងការគ្រប់គ្រង ពេលធ្វើក្នុងសាលារៀនមួយដោយសារសិស្ស និងគ្រូទាំងអស់ស្ថិតនៅកន្លែងតែមួយ។ ក្នុងករណីខ្លះសាលារៀនមួយចំនួន ដែលនៅក្បែរគ្នាក្នុងតំបន់គោលដៅក៏អាចចូលរួមក្នុងក្លឹបអាស៊ាននេះបានដែរ។ ករណីនោះសាលាមធ្យមសិក្សាធនធានដើរតួជាអ្នកសម្របសម្រួល។ ប្រសិនបើមានសាលារៀនមួយចំនួនកំពុងអនុវត្តក្លឹបអាស៊ាន នាយកសាលាបណ្ដាញទាំងនោះ អាចសម្រេចចិត្តដាក់ធនធានរួមគ្នាសម្រាប់ធ្វើសកម្មភាពដូចជា ទស្សនកិច្ចសិក្សា ពិព័រណ៍ស្នាដៃសិស្ស។ល។ ការអនុវត្តសកម្មភាពរួមគ្នា អាចមានអត្ថប្រយោជន៍មួយចំនួនដូចជា ការជៀសវាងធ្វើសកម្មភាពជាន់គ្នា ជាពិសេសករណីដំណើរទស្សនកិច្ចសិក្សា។ ទោះបីជាយ៉ាងណាក៏ដោយ ការសម្របសម្រួលក្នុងកម្រិតនេះ ពេលខ្លះអាចជួបបញ្ហាប្រឈម។ នាយកសាលាដែលពាក់ព័ន្ធគួរពិនិត្យមើលកម្រិតចំណាប់អារម្មណ៍ចូលរួមក្នុងក្លឹបអាស៊ានពីសាលារៀនមួយចំនួន ចម្ងាយរវាងសាលារៀន និងការពេញចិត្តរបស់គ្រូដឹកនាំនៅពេលសម្រេចចិត្តថាតើត្រូវរៀបចំក្លឹបរួមគ្នា ឬដាច់ដោយឡែក។ ក្នុងករណីអនុវត្តសកម្មភាពរួមគ្នាគេត្រូវចាត់ចែងថវិកាដែលចាំបាច់សម្រាប់ការធ្វើដំណើរសម្របសម្រួលកិច្ចប្រជុំអន្តរសាលា។

### ៤.១.៣. កម្រិតថ្នាក់គោលដៅ

ការចូលរួមក្លឹបអាស៊ាន គឺជាសកម្មភាពមួយដែលលើកដំបូងយើងត្រូវកំណត់ជ្រើសរើសយកសិស្សពេញវ័យ។ នៅពេលដែលសាលាមានបទពិសោធន៍ច្រើនពីការរៀបចំក្លឹបនេះហើយ គ្រូអាចធ្វើការសាកល្បងរៀបចំសកម្មភាពក្លឹបដែលសមរម្យទៅនឹងសិស្សតូចៗបាន។ ប៉ុន្តែសម្រាប់សាលាមធ្យមសិក្សា ក្លឹបនេះអាចរៀបចំនៅកម្រិតថ្នាក់ទីប៉ុន្មានក៏បាន អាស្រ័យលើលទ្ធភាពរបស់គ្រូ ថាតើគាត់ចាប់អារម្មណ៍ក្នុងការងារនេះឬយ៉ាងណា។

### ៤.១.៤. ការវាយតម្លៃចំណាប់អារម្មណ៍សិស្ស និងការតម្រង់ទិស

ការចូលរួមក្លឹប គឺអាស្រ័យលើការសម្រេចចិត្តរបស់សិស្សផ្ទាល់។ ការវាយតម្លៃចំណាប់អារម្មណ៍សិស្សពីការចូលរួមក្លឹបនេះ គ្រូត្រូវពន្យល់ណែនាំពីអត្ថន័យក្លឹបនោះជាមុនសិន។ ការណែនាំនេះអាចនិយាយផ្ទាល់មាត់ទៅកាន់សិស្សក្នុងថ្នាក់ ឬអាចសរសេរបិទនៅទីធ្លាបរិវេណសាលា ឬយើងអាចប្រើវិធីទាំងពីរនេះតែម្ដង។ សេចក្ដីណែនាំទាំងអស់រួមមានចំណុចដូចខាងក្រោមនេះ៖

- **វត្ថុបំណង៖** ដើម្បីបង្កើនការយល់ដឹងរបស់សិស្សពីអង្គការអន្តររដ្ឋាភិបាលក្នុងតំបន់ និងបណ្ដាប្រទេសជាសមាជិក។
- **សកម្មភាព៖** ការស្រាវជ្រាវជាក្រុមតាមរយៈប្រព័ន្ធកុំព្យូទ័រ សៀវភៅ ការធ្វើបទសម្ភាស ការតាំងពិព័រណ៍

ជារៀងរាល់ខែពីប្រទេសអាស៊ាន និងការបង្កើតប្រអប់សំណុំឯកសារបទបង្ហាញរាល់ការធ្វើទស្សនកិច្ចសិក្សា។

- **ការវាយតម្លៃ៖** ពុំមានការវាយតម្លៃ ឬដាក់ពិន្ទុជាលក្ខណៈផ្លូវការទេ គឺសិស្សចូលរួមក្នុងសកម្មភាពក្លឹបដោយការពេញចិត្តរបស់ពួកគេ ពុំមែនដោយសារការបង្ខំឡើយ។
- **ការចូលរួម៖** សមាជិកភាពក្លឹបចូលរួមដោយស្ម័គ្រចិត្ត។
- **ការប្រជុំ៖** ការប្រជុំសាមញ្ញ (ប្រហែល២សប្តាហ៍ម្តង) ដើម្បីពិភាក្សាពីសកម្មភាពដែលបានគ្រោងទុក។ ចំណុចខាងលើនេះ ត្រូវអនុវត្តក្រៅម៉ោងសិក្សា ឬថ្ងៃឈប់សម្រាក។

អនុវត្តតាមសេចក្តីណែនាំនេះ គ្រូត្រូវសួរសិស្សថាតើពួកគេចាប់អារម្មណ៍ក្នុងការចូលរួមក្លឹបនេះ ឬទេ ហើយកំណត់ឱ្យបានពីកម្រិតនៃការចាប់អារម្មណ៍របស់ពួកគេ។ ការវាយតម្លៃចំណាប់អារម្មណ៍សិស្ស គ្រូត្រូវប្រើទម្រង់ដែលមានក្នុង**ឧបសម្ព័ន្ធទី១**។ ទម្រង់នេះមានប្រយោជន៍ ពីព្រោះវាទប់ស្កាត់មិនឱ្យមានការគាបសង្កត់ និងបង្ខំសិស្សឱ្យនិយាយថា យល់ព្រម ឬ មិនយល់ព្រម ជាពិសេសនៅចំពោះមុខគ្រូ សិស្សបង្ហាញនូវភាពមិនស្មោះត្រង់។ អាស្រ័យហេតុនេះ គ្រូត្រូវផ្តល់ពេលឱ្យសិស្សរយៈពេលពី ១០ ទៅ ១៥នាទី ដើម្បីឱ្យពួកគេធ្វើការសម្រេចចិត្តមុនពេលបំពេញទម្រង់ និងមុនពេលប្រគល់ទម្រង់នោះជូនគ្រូវិញ។

### ៤.១.៥. ការបែងចែកនាទីកិច្ច

នៅពេលមានកិច្ចប្រជុំក្លឹបជាលើកដំបូង គ្រូដឹកនាំក្លឹប ត្រូវជ្រើសរើសសមាជិកមួយចំនួនដើម្បីទទួលខុសត្រូវលើកិច្ចការនានា។ ការជ្រើសរើសនេះ ធ្វើឡើងដោយការបោះឆ្នោត ឬ តាមរយៈការលើកដៃ។ តួនាទីគឺមិនទៀងទាត់ទេ រួមមាន ១)ប្រធាន ២)អនុប្រធាន និង ៣)ហិរញ្ញិក។ ប្រសិនបើមានសិស្សច្រើននាក់នៅក្នុងក្លឹប (ឧ. ១៥នាក់ ឬច្រើនជាងនេះ) ចាំបាច់ត្រូវមានប្រធានក្រុម ១នាក់ សម្រាប់សម្របសម្រួលសិស្ស ៣ ឬ ៤នាក់នោះ។ ការទទួលខុសត្រូវនេះបានភ្ជាប់ជូនក្នុង**ឧបសម្ព័ន្ធទី២**។ គ្រូដឹកនាំក្លឹបត្រូវពន្យល់ និងបង្ហាញដល់សមាជិកក្លឹបទាំងអស់។ នៅក្នុងជំហានដំបូងនៃសកម្មភាពក្លឹប គ្រូដឹកនាំត្រូវទទួលខុសត្រូវក្នុងការចូលរួមចំណែកជួយសមាជិកក្លឹប ដើម្បីឱ្យពួកគេមានទំនាក់ទំនងគ្នា និងបំពេញតួនាទីបានល្អ។ ជាមួយគ្នានោះដែរ គ្រូដឹកនាំត្រូវខិតខំប្រឹងប្រែងបំពេញភារកិច្ចឱ្យបានល្អដើម្បីជួយសិស្សឱ្យទទួលបានបទពិសោធន៍ការងារល្អប្រសើរ។

### ៤.១.៦. ការកំណត់ផែនការ

កិច្ចការមួយក្នុងចំណោមកិច្ចការទាំងឡាយដែលក្លឹបត្រូវធ្វើគឺ ការរៀបចំផែនការសកម្មភាពដែលបានស្នើសុំក្នុងរយៈពេល ១ត្រីមាស។ ទម្រង់ផែនការសកម្មភាពក្លឹបមានលក្ខណៈសមស្របពីមួយសប្តាហ៍ទៅមួយសប្តាហ៍ក្នុងខែនីមួយៗ ដូចបានភ្ជាប់ជូនក្នុង**ឧបសម្ព័ន្ធទី៣**។ មុនពេលធ្វើផែនការគ្រូគួរព្យាយាមពិនិត្យមើលថាតើសកម្មភាពណាដែលអាចធ្វើទៅបាន ហើយកំណត់យកគម្រោង១ ឬ ២ ដែលក្លឹបនឹងអនុវត្តក្នុងត្រីមាសនីមួយៗ។ ឧទាហរណ៍ ក្លឹបចង់ឱ្យសិស្សសិក្សាពីរចនាសម្ព័ន្ធអាស៊ាន មុននឹងសិក្សាស៊ីជម្រៅពីរដ្ឋសមាជិកអាស៊ាន។ ដើម្បីឱ្យសិស្សយល់ដឹងពីអាស៊ាន គ្រូអាចបង្ហាញឃ្លីបវីដេអូខ្លីៗមួយចំនួនដល់សិស្ស ហើយសិស្សអាចធ្វើការស្រាវជ្រាវព័ត៌មានបន្ថែមពីប្រទេសសមាជិកអាស៊ាននីមួយៗ។ នៅពេលការសិក្សាស្រាវជ្រាវបញ្ចប់ ក្លឹបត្រូវ

រៀបចំការដាក់តាំងពិព័រណ៍ក្នុងបណ្ណាល័យ ឬថ្នាក់រៀន ព្រមទាំងធ្វើបទបង្ហាញពីអ្វីដែលបានស្រាវជ្រាវនោះទៅដល់សិស្សដទៃទៀតដែលមិនមែនជាសមាជិករបស់ក្លឹប។ គ្រប់សកម្មភាពទាំងនេះ គួរតែសរសេរទុកនៅក្នុងផែនការ។ សូមមើលឧទាហរណ៍ក្នុងតារាងខាងក្រោម៖

**តារាងទី១៖ ការកំណត់ផែនការ**

**ត្រីមាសទី១**

| សកម្មភាព | វិច្ឆិកា | | | | ធ្នូ | | | | មករា | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| ១. សកម្មភាពទី១៖ ការបោះឆ្នោតជ្រើសរើស និងការពិភាក្សាពីសកម្មភាព | x | | | | | | | | | | | |
| ២. សកម្មភាពទី២៖ ការស្រាវជ្រាវបឋមពីអាស៊ាន | | X | | | | | | | | | | |
| ៣. សកម្មភាពទី៣៖ ការស្រាវជ្រាវពីកម្ពុជា | | | x | x | | | | | | | | |
| ៤. សកម្មភាពទី៤៖ ធ្វើផែនការសម្រាប់ការតាំងពិព័រណ៍។ កំណត់កិច្ចការដែលត្រូវធ្វើ និងអ្នកទទួលខុសត្រូវ | | | | x | | | | | | | | |
| ៥. សកម្មភាពទី៥៖ ការបង្កើតក្តារខៀនព័ត៌មានមួយពីប្រទេសកម្ពុជា | | | | | x | | | | | | | |
| ៦. សកម្មភាពទី៦៖ ប្រជុំគ្នាដើម្បីរៀបចំការតាំងពិព័រណ៍ក្នុងមជ្ឈមណ្ឌលរបស់សាលា | | | | | | x | | | | | | |
| ៧. សកម្មភាពទី៧៖ ការស្រាវជ្រាវពីប្រទេសមួយផ្សេងទៀត | | | | | | | x | x | | | | |
| ៨. សកម្មភាពទី៨៖ ការមើលភាពយន្តមួយពីប្រទេសជាសមាជិកអាស៊ាន | | | | | | | | | x | | | |
| ៩. សកម្មភាពទី៩៖ បំពេញការស្រាវជ្រាវពីប្រទេសទាំងនោះ | | | | | | | | | | x | x | |

### ៤.១.៧. ការកំណត់ធនធាន

ដើម្បីធ្វើឱ្យសកម្មភាពក្លឹបប្រកបដោយប្រសិទ្ធភាព ជាការចាំបាច់ត្រូវមានធនធានសម្ភារៈទាំងឡាយដូចជា កន្លែងប្រជុំ(បណ្ណាល័យ ឬថ្នាក់រៀនទំនេរ) សៀវភៅក្នុងបណ្ណាល័យសម្រាប់ការសិក្សាស្រាវជ្រាវ បន្ទប់

កុំព្យូទ័រសម្រាប់សរសេររបាយការណ៍ (ប្រើចំពោះថ្នាក់មធ្យមសិក្សា) ឬធនធានថវិកា។ ធនធានថវិកាជាតម្រូវការសម្រាប់អនុវត្តសកម្មភាពជាក់ស្តែងដូចខាងក្រោម៖

- ក្រដាសសម្រាប់កត់ត្រា ឬសរសេររបាយការណ៍ (សម្រាប់ក្រុមទាំងអស់)
- ក្រដាសផ្ទាំងធំសម្រាប់គូផែនទី ធ្វើការដាក់តាំងពិព័រណ៍ ប្រជុំ
- ហ្វឹតសម្រាប់សរសេររៀបចំតាំងពិព័រណ៍
- ថវិកាធ្វើដំណើរទស្សនកិច្ចសិក្សា
- ម៉ាស៊ីនថតរូប
- ថវិកាសម្រាប់ចំណាយផ្សេងៗ។

ថវិកាក្លឹបត្រូវបានរៀបចំឡើងដោយគណៈកម្មការគ្រប់គ្រងសាលាក្នុងពេលដំណើរការរៀបចំផែនការប្រចាំឆ្នាំដែលធ្វើឡើងនៅដើមឆ្នាំសិក្សានីមួយៗ។ សូមមើលក្នុង**ឧបសម្ព័ន្ធទី៤**។

### ៤.២. សកម្មភាពស្នើឡើង

សកម្មភាពជាច្រើនដែលក្លឹបនេះអាចរៀបចំឱ្យមានកិច្ចការ (លំហាត់) មើលទៅគួរឱ្យចាប់អារម្មណ៍ និងមានលក្ខណៈគិតស៊ីជម្រៅសម្រាប់សិស្ស រីឯសកម្មភាពដែលបានផ្តល់ឱ្យនៅខាងក្រោមនេះគឺគ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ។ គ្រូ និងសមាជិកក្លឹប អាចបញ្ចេញយោបល់ផ្ទាល់ខ្លួនពីអ្វីដែលពួកគេចង់ធ្វើដើម្បីបង្កើនឱកាសរៀនសូត្រតាមរយៈការសិក្សានិងដោះស្រាយបញ្ហាអាស៊ានឱ្យបានស៊ីជម្រៅ។

សកម្មភាពគួរដាក់បញ្ចូលនូវការស្រាវជ្រាវតាមប្រព័ន្ធកុំព្យូទ័រ សៀវភៅ ការស្រាវជ្រាវពីរដ្ឋសមាជិកអាស៊ានតាមរយៈខ្សែភាពយន្ត ឬឯកសារជាតិ ការធ្វើបទបង្ហាញបែបច្នៃប្រតិដ្ឋ និងការរៀបចំប្រអប់សំណុំឯកសារអាស៊ាន។ សកម្មភាពទាំងអស់នេះ នឹងជំរុញសិស្សឱ្យមានបំណិនក្នុងការត្រិះរិះពិចារណា ស្រាវជ្រាវ និងការរៀបចំ។ ស្របពេលបច្ចុប្បន្ននេះ ការស្រាវជ្រាវព័ត៌មានតាមប្រព័ន្ធកុំព្យូទ័រ និងសៀវភៅ គួរក្លាយជាទម្លាប់សម្រាប់សិស្សក្នុងការសិក្សាប្រចាំថ្ងៃរបស់ពួកគេ។ វាក៏ផ្តល់ឱកាសឱ្យសិស្សក្នុងការគិត និងពិភាក្សាជាមួយគ្រូពីអ្វីជាសមាជិកអាស៊ាន។

ពេលចាប់ផ្តើមក្លឹបនេះ គំនិតល្អមួយដែលគ្រូត្រូវរៀបចំគឺ ប្រធានបទប្រជុំលើកទី១ ដោយគិតថា សិស្សអាចនឹងមិនមានបទពិសោធន៍ពីបញ្ញត្តិអាស៊ាននោះទេ។ ចំណុចចាប់ផ្តើមដ៏ល្អមួយ គ្រូគួរតែណែនាំសិស្សឱ្យស្គាល់ពីសហគមន៍អាស៊ាន បន្ទាប់មកត្រូវបង្ហាញពីបណ្តាប្រទេសជាសមាជិកអាស៊ានម្តងមួយៗ។ ក្រោយមកទៀត សិស្សត្រូវចូលរួម និងទទួលខុសត្រូវឱ្យបានច្រើន។ ការចូលរួមក្នុងក្លឹប គឺជាការស្ម័គ្រចិត្ត ដូចនេះជាការចាំបាច់គ្រូត្រូវគោរពតាមចំណាប់អារម្មណ៍សិស្ស និងអនុញ្ញាតឱ្យពួកគេលើកឡើងពីប្រធានបទ ឬសកម្មភាពដែលពួកគេចង់រៀន។

#### ៤.២.១. ការយល់ដឹងពីអាស៊ាន

ដំបូងគ្រូត្រូវពន្យល់សិស្សពីសហគមន៍អាស៊ាន និងជំរុញសិស្សឱ្យចូលរួមធ្វើការស្រាវជ្រាវ។ នៅពេលដែលសិស្សស្រាវជ្រាវដោយខ្លួនឯង នឹងធ្វើឱ្យពួកគេមានការចងចាំបានល្អរាល់ព័ត៌មានដែលបានប្រមូល។ ការ

យល់ដឹងពីអាស៊ាន មានសារៈសំខាន់ក្នុងការស្វែងយល់ពីបរិបទថ្នាក់តំបន់ និងអន្តរជាតិក្នុងពេលបច្ចុប្បន្ន។ វាក៏មានសារៈសំខាន់ផងដែរ ក្នុងការស្វែងយល់ពីសហគមន៍អាស៊ាន មុនពេលសិក្សាស៊ីជម្រៅពីរដ្ឋសមាជិកអាស៊ាន។ ការរៀនសូត្រពីអាស៊ាន រួមបញ្ចូលនូវរចនាសម្ព័ន្ធ សមាជិកភាព គោលបំណង និងគោលវិធីរបស់វា។ វាក៏គួរឱ្យចាប់អារម្មណ៍ក្នុងការស្វែងយល់ពីភាពសំខាន់ សមិទ្ធផល និងបញ្ហាប្រឈមក្នុងពេលអនាគតរបស់សមាជិកអាស៊ាន។ សកម្មភាពជាគំនិតនានាបានភ្ជាប់ជូនៈ

## ការយល់ដឹងពីអាស៊ាន

**វត្ថុបំណង៖** ដើម្បីជួយលើកទឹកចិត្តសិស្សឱ្យទទួលបានចំណេះដឹងទូទៅពីសហគមន៍អាស៊ាន។

**សម្ភារៈ ៖** ប៊ិក និងក្រដាស

**១. ល្បែងត្រៀម៖** សូមទាយមើល "តើខ្ញុំជានរណា?"

ខណៈដែលគ្រូនិយាយឈ្មោះមិនពេញលេញមួយ សិស្សធ្វើការជាគូរ ដោយទស្សន៍ទាយតាមរយៈការសរសេរឈ្មោះប្រទេស ឈ្មោះទីក្រុង រូបិយវត្ថុ ភាសា ឬអ្វីមួយ។ គ្រូ និងសិស្ស នឹងត្រូវប្រៀបធៀបចម្លើយរបស់ពួកគេ។ ប្រសិនបើចម្លើយខ្លះខុសគ្នា ពួកគេនឹងត្រូវស្វែងរកចម្លើយដែលត្រឹមត្រូវនៅក្នុងឯកសារស្រាវជ្រាវ។

ទាយមើល តើខ្ញុំជានរណា?
- ខ្ញុំមានប្រាសាទមួយនៅចំកណ្តាលទង់ជាតិខ្ញុំ...
- ខ្ញុំគឺជារដ្ឋសមាជិកអាស៊ានតូចជាងគេបំផុត...
- ខ្ញុំគឺជារដ្ឋសមាជិកអាស៊ានដែលមានចំនួនប្រជាជនច្រើនជាងគេបំផុត...
- ខ្ញុំមានពណ៌តែ ២គត់ នៅលើទង់ជាតិរបស់ខ្ញុំ...(មានចម្លើយ២៖ វៀតណាម (ក្រហម និងលឿង) និង ឥណ្ឌូនេស៊ី (ក្រហម និងស)
- ខ្ញុំគឺជាប្រជាជាតិមូស្លីមធំជាងគេបង្អស់ក្នុងពិភពលោក...
- ខ្ញុំគឺជាប្រជាជាតិគ្រីស្ទានធំជាងគេបង្អស់នៅក្នុងអាស៊ាន ឬអាស៊ី...
- ពួកយើងគឺជាអ្នកសង្កេតការណ៍ទាំងពីរនៅឯកិច្ចប្រជុំអាស៊ាន...
- ខ្ញុំគឺជាទឹកដីនៃស្នាមញញឹម...
- ខ្ញុំគឺជាប្រទេសចុងក្រោយគេដែលចូលរួមជាសមាជិកអាស៊ាន...
- ខ្ញុំគឺជារាជធានីនៃប្រទេសម៉ាឡេស៊ី...
- ខ្ញុំបានដាក់អាណានិគមដោយប្រទេសអេស្ប៉ាញ បន្ទាប់មកដោយសហរដ្ឋអាមេរិក...
- ខ្ញុំគឺជាស៊ុលតង់តែមួយគត់នៅក្នុងអាស៊ាន...
- ខ្ញុំគឺជារូបិយវត្ថុដែលប្រើប្រាស់នៅក្នុងប្រទេសឡាវ...
- ខ្ញុំធ្លាប់បានគេហៅថា សាយហ្គន...

**២. ការធ្វើតេស្តខ្លីៗពីអាស៊ាន**

**សម្ភារៈ៖** សៀវភៅ និងកុំព្យូទ័រ

**ការគាំទ្រ៖** https://www.youtube.com/watch?v=YrnK5UQDdO0 (មានអក្សររត់លើអេក្រង់ជាភាសា

អង់គ្លេស)

**នីតិវិធី៖**

គ្រូចាប់ផ្តើមដោយសួរសំណួរទាំងឡាយ (សូមមើលឧទាហរណ៍ខាងក្រោម)។ សិស្សធ្វើការជាក្រុមតូចៗដោយព្យាយាមឆ្លើយសំណួរឱ្យបានច្រើនតាមដែលអាចធ្វើបាន។ បន្ទាប់មក គ្រូបង្ហាញខ្សែវីដេអូខ្លីមួយ (តំណភ្ជាប់ខាងលើ) ដល់សិស្ស។ សិស្សត្រូវបំពេញ ឬផ្លាស់ប្តូរចម្លើយជាមួយព័ត៌មានបន្ថែមពីអាស៊ាន ដែលពួកគេបានរៀនសូត្រពីវីដេអូនោះ។ ប្រសិនបើចាំបាច់ សិស្សត្រូវធ្វើការស្រាវជ្រាវបន្ថែមនៅក្នុងសៀវភៅ និងតាមប្រព័ន្ធកុំព្យូទ័រ។ នៅពេលបញ្ចប់វគ្គនេះ គ្រូ និងសិស្សត្រូវធ្វើការពិភាក្សាក្រុមដើម្បីចែករំលែកចម្លើយ។

**ឧទាហរណ៍ពីសំណួរសម្រាប់ការធ្វើតេស្តខ្លីៗ៖**

- តើអាស៊ានបង្កើតឡើងនៅពេលណា? ហើយប្រទេសណាខ្លះជាសមាជិកស្ថាបនិក?
- សូមរាប់ឈ្មោះ និងរកទីតាំងរដ្ឋសមាជិកអាស៊ាន និងរាជធានីរបស់ពួកគេនៅលើផែនទី។
- តើពាក្យកាត់ A.S.E.A.N. តំណាងឱ្យអ្វី?
- តើគោលដៅធំៗរបស់អាស៊ានមានអ្វីខ្លះ?
- តើរូបសញ្ញាអាស៊ានមានអត្ថន័យដូចម្តេចខ្លះ? (ចូរគូសរូប និងផាត់ពណ៌)
- តើភាសាអ្វីដែលត្រូវបានជ្រើសរើសជាភាសាផ្លូវការសម្រាប់កិច្ចប្រជុំអាស៊ាន? ហេតុអ្វី?
- តើហេតុអ្វីបានជាប្រជាជាតិនានាបង្កើត និងចូលរួមជាសមាជិកអាស៊ាន?
- តើរដ្ឋសមាជិកអាស៊ានមានគោលដៅរួមអ្វីខ្លះ?
- តើអាស៊ានមានបាវចនាអ្វីខ្លះ?
- តើប្រធានអាស៊ានធ្វើការដូចម្តេចខ្លះ?
- តើកម្ពុជាចូលជាសមាជិកអាស៊ាននៅថ្ងៃ ខែ ឆ្នាំណា?
- សូមរាប់សេចក្តីថ្លែងការណ៍ជាគោលការណ៍របស់អាស៊ានឱ្យបានច្រើនតាមដែលអ្នកអាចធ្វើបាន។
- ហេតុអ្វីបានជាឆ្នាំ២០១៥ គឺជាឆ្នាំគន្លឹះសម្រាប់អាស៊ាន? តើមានអ្វីថ្មីក្នុងឆ្នាំ២០១៥ សម្រាប់អាស៊ាន?
- តើប្រទេសអាស៊ានទាំងអស់មានរចនាសម្ព័ន្ធនយោបាយដូចគ្នាដែរឬទេ? បើខុសគ្នា តើខុសដូចម្តេចខ្លះ?
- តើអ្វីជាគោលបំណងនៃសេចក្តីថ្លែងការណ៍អាស៊ាន?
- ចូររាប់ឈ្មោះគោលការណ៍អាស៊ានឱ្យបានច្រើនតាមដែលអ្នកអាចធ្វើបាន។
- តើប្រធានអាស៊ានធ្វើការដូចម្តេចខ្លះ?
- តើលេខាធិការដ្ឋានអាស៊ានស្ថិតនៅឯណា?
- តើសសរទ្រូងទាំងបីរបស់អាស៊ានមានអ្វីខ្លះ? (តម្រុយ៖ សហគមន៍ ៣)
- ហេតុអ្វីបានជាឥណ្ឌា ឬជប៉ុនមិនមែនជារដ្ឋសមាជិកអាស៊ាន?
- តើទីក្រុងមួយណាជាទីក្រុងអាស៊ានធំជាងគេ?
- តើអាស៊ានបូក ៣ គឺជាអ្វី?

**ចម្លើយ៖ សូមមើលតំណភ្ជាប់ខាងក្រោម៖**

- http://www.asean.org/
- http://www.eduinitiatives.org/sites/default/files/ASEAN%20Unit.pdf
- http://en.wikipedia.org/wiki/Association_of_Southeast_Asian_Nations

ចូរស្វែងរកទីតាំងរដ្ឋសមាជិកអាស៊ាននៅលើផែនទីខាងក្រោមនេះ។



៤.២.២. ការស្រាវជ្រាវពីរដ្ឋសមាជិកអាស៊ាន

ការស្រាវជ្រាវពីរដ្ឋសមាជិកអាស៊ាន ដោយប្រើប្រព័ន្ធកុំព្យូទ័រ និងសៀវភៅ នឹងធ្វើឱ្យសិស្សសកម្ម។ វាក៏ជាមធ្យោបាយល្អមួយសម្រាប់ពួកគេ ក្នុងការចងចាំព័ត៌មានដែលបានរកឃើញ និងចែករំលែកជាមួយសិស្សដទៃទៀត។ ប្រទេសដែលជាសមាជិកអាស៊ាននឹងត្រូវណែនាំឱ្យសិស្សស្គាល់រាល់ ៣-៤ សប្តាហ៍ម្តង ហើយដំណើរការនេះត្រូវធ្វើតាមគំរូដូចគ្នាសម្រាប់បណ្តាប្រទេសទាំងអស់។ តាមរយៈការប្រើប្រាស់គំរូដូចគ្នានេះ សិស្សនឹងអាចធ្វើការប្រៀបធៀបគ្នារវាងរដ្ឋសមាជិកអាស៊ាន(លក្ខណៈខុសគ្នា និងដូចគ្នា)។ ក្លឹបគួរចាប់ផ្តើមជាមួយនឹងប្រទេសកម្ពុជា និងបន្តសិក្សាលើប្រទេសជិតខាង។

**១. ការរៀនសូត្រតាមរយៈខ្សែភាពយន្ត**

ជាការសំខាន់ក្នុងបង្កើតវិធីរៀនឱ្យមានលក្ខណៈផ្សេងៗគ្នា ដើម្បីឱ្យសិស្សមានចំណាប់អារម្មណ៍។ ដូច្នេះ ការសិក្សាពីប្រទេសអាស៊ាន អាចប្រើវិធីមើលខ្សែភាពយន្ត ឬឯកសារសម្រាប់ប្រទេសជាក់លាក់ណាមួយ។ សិស្សត្រូវកត់ត្រាពីអ្វីមួយដែលពួកគេយល់ថាវាគួរឱ្យចាប់អារម្មណ៍ (ធ្វើតាមគំរូប្រទេសដែលបានសិក្សាមុនគេ

ជាឧទាហរណ៍)។

### ៤.២.២.២ ការអញ្ជើញវាគ្មិន

ការអញ្ជើញវាគ្មិន គឺជាវិធីបន្ថែមមួយទៀតក្នុងការរៀនពីរដ្ឋសមាជិកអាស៊ាន។ សមាជិកក្លឹបអាចអញ្ជើញវាគ្មិនកិត្តិយសណាម្នាក់ (ឧ. បុគ្គលម្នាក់ពីប្រទេសអាស៊ាន ឬសាស្ត្រាចារ្យមួយរូបពីសាកលវិទ្យាល័យវេស្ទើន)។ សាកលវិទ្យាល័យវេស្ទើន បានបើកថ្នាក់បរិញ្ញាបត្រស្តីពីច្បាប់អាស៊ាន។ វាគួរឱ្យចាប់អារម្មណ៍សម្រាប់សិស្សក្នុងការពិភាក្សាជាមួយគ្រូនៅសាកលវិទ្យាល័យពីវប្បធម៌អាស៊ាន។ លើសពីនេះទៀត សិស្សនឹងទទួលបានឱកាសក្នុងការកែលម្អបំណិនប្រាស្រ័យទាក់ទងរបស់ពួកគេដោយការរៀបចំសំណួរ ការកត់ត្រា និងការនិយាយជាសាធារណៈ។

## ការស្រាវជ្រាវពីរដ្ឋសមាជិកអាស៊ាន

**វត្ថុបំណង៖** ជួយសិស្សអភិវឌ្ឍបំណិនស្រាវជ្រាវ អភិវឌ្ឍន៍ចំណេះដឹងរបស់ពួកគេពីលក្ខណៈនៃបណ្តាប្រទេសជិតខាង។

**សម្ភារៈ៖** បន្ទប់កុំព្យូទ័រ សៀវភៅ ក្រដាស ប៊ិក...

**១. ល្បែងត្រៀម៖** «ការប្រមូលផ្តុំគំនិត»

គ្រូរៀបចំវគ្គប្រមូលផ្តុំគំនិត ដើម្បីណែនាំសិស្សឱ្យស្គាល់ពីរដ្ឋសមាជិកអាស៊ាន។ សិស្សប្រមូលផ្តុំគ្នានៅបណ្ណាល័យ ឬមជ្ឈមណ្ឌលមេឌៀ ហើយគ្រូសួរពួកគេថា «តើអ្នកដឹងអ្វីខ្លះពីប្រទេសថៃ វៀតណាម ឥណ្ឌូណេស៊ី...?» សិស្សម្នាក់ៗ (ឆ្លើយម្តងម្នាក់ៗ) ផ្តល់គំនិតរបស់ខ្លួនពីប្រទេសទាំងនោះ។ សិស្ស ឬគ្រូសរសេរចម្លើយនៅលើក្រដាសផ្ទាំងធំនូវគំនិតរបស់ពួកគេ។ នៅពេលសិស្សពុំមានគំនិតបន្ថែមនោះទេ គ្រូត្រូវផ្តល់ជំនួយជាគន្លឹះដល់សិស្ស ហើយសិស្សត្រូវព្យាយាមចាត់ថ្នាក់គំនិតទៅតាមប្រភេទ (ឧ. ព័ត៌មានទូទៅ នយោបាយ សេដ្ឋកិច្ច ការអប់រំ ប្រពៃណី ទិដ្ឋភាពភូមិសាស្ត្រ ប្រវត្តិសាស្ត្រ...)។ ល្បែងត្រៀមនេះ គួរមានរយៈពេលច្រើនបំផុត ៣០ នាទី។

### ២. ការធ្វើបណ្ណប្រទេស

- **វត្ថុបំណង៖** ដើម្បីលើកទឹកចិត្តសិស្សក្នុងការស្រាវជ្រាវលើវប្បធម៌បណ្តាប្រទេសអាស៊ាន។
- **សម្ភារៈ៖** ឌីវីឌី ឬខ្សែភាពយន្ត ទូរទស្សន៍ ប៊ិច និងក្រដាស
- **រយៈពេល៖** ការស្រាវជ្រាវពីប្រទេសសមាជិកអាស៊ានអាចចំណាយពេលលើសពី ១វគ្គ
- **ព័ត៌មានដែលស្នើឱ្យប្រមូល៖** គំរូប្រទេសដែលស្នើជាយោបល់

**គូសផែនទី និងស្វែងរកប្រទេសនោះនៅលើផែនទី**

**<u>ព័ត៌មានទូទៅ៖</u>**

ឈ្មោះផ្លូវការរបស់ប្រទេស

បាវចនាជាតិ

រាជធានី

ទីក្រុងធំបំផុត

ភាសាផ្លូវការ និងរបៀបនិយាយ « សួស្តី » ជាភាសាផ្លូវការ
រូបិយវត្ថុ
សាសនាធំៗដែលបានប្រតិបត្តិ (គិតជា%)
ផ្ទៃក្រឡាសរុប
ចំនួនប្រជាជនសរុប
ដង់ស៊ីតេប្រជាជន
ក្រុមជនជាតិ (គិតជា%)

**<u>លក្ខណៈពិសេសរបស់ជាតិ៖</u>**

ក្បួនធ្វើម្ហូប
ផ្កាតំណាង
សម្លៀកបំពាក់
ការឈប់សម្រាកបុណ្យជាតិ (រួមនឹងការពន្យល់បកស្រាយ)
កីឡាជាតិទាំងឡាយ
ប្រាសាទ ឬវិមានល្បីៗ

**<u>ប្រវត្តិសាស្ត្រ៖</u>**

ទិវាឯករាជ្យជាតិ
សាវតាប្រវត្តិសាស្ត្រពាក់ព័ន្ធការដាក់អាណានិគម សង្គ្រាមទាំងឡាយ...
ឆ្នាំចូលជាសមាជិកអាស៊ាន

**<u>ភូមិសាស្ត្រ៖</u>**

អាកាសធាតុ (រដូវវស្សា និងរដូវប្រាំង)
ខ្ពង់រាប ឬភ្នំខ្ពស់ជាងគេបំផុត
ផ្លូវទៅកាន់សមុទ្រ ឬទន្លេសំខាន់ៗ
បំណែងចែករដ្ឋបាល

**<u>ទិដ្ឋភាពនយោបាយ៖</u>**

នាយករដ្ឋមន្ត្រីបច្ចុប្បន្ន ប្រធានាធិបតី ស៊ុលតង់ ឬព្រះមហាក្សត្រ → អ្នកគ្រងរាជ្យប្រទេស
រដ្ឋាភិបាល និងគណបក្សនយោបាយ
លក្ខខណ្ឌសិទ្ធិមនុស្ស

**<u>បរិយាកាសសេដ្ឋកិច្ច៖</u>**

ជីឌីភី (GDP)
ផលិតផលសំខាន់ៗ និងទីតាំងនៅក្នុងប្រទេសដែលបានផលិត
សារៈសំខាន់នៃការនាំចេញ
ការបង្កបង្កើនផល

ទេសចរណ៍

**ប្រព័ន្ធអប់រំ៖**

ឆ្នាំសរុបនៃការសិក្សាកំណត់ដោយច្បាប់ (បឋមសិក្សា មធ្យមសិក្សា (បឋមភូមិ-ទុតិយភូមិ))

សាកលវិទ្យាល័យ (បរិញ្ញាបត្រ-បរិញ្ញាបត្រជាន់ខ្ពស់)

អត្រាចុះឈ្មោះចូលរៀនសុទ្ធ (NER) សម្រាប់សាលាបឋមសិក្សា និងមធ្យមសិក្សា

**វិធីស្វែងរកព័ត៌មានពីប្រទេស៖**

- **ការស្រាវជ្រាវតាមប្រព័ន្ធកុំព្យូទ័រ និងបណ្ណាល័យ**

សិស្សស្វែងរកព័ត៌មានពីប្រទេសដោយខ្លួនឯង ទោះតាមរយៈសៀវភៅដែលមាននៅបណ្ណាល័យ ឬតាមកុំព្យូទ័រក្តី។ សិស្សក្នុងក្លឹបគួរមានការយល់ដឹងលើការប្រើបណ្ណាល័យ ឬកុំព្យូទ័រដែលជាប្រភពព័ត៌មាន។ គ្រូបែងចែកសិស្សឱ្យធ្វើការជាក្រុមតូចៗ រួចហើយផ្តល់ព័ត៌មានដល់ក្រុមសិស្សធ្វើការស្រាវជ្រាវ។ តាមរយៈការធ្វើការជាមួយគ្នា សិស្សនឹងបានរៀនសូត្រពីការធ្វើការងារជាក្រុម។ នៅចុងបញ្ចប់នៃការស្រាវជ្រាវ សិស្សគួរធ្វើបទបង្ហាញលទ្ធផលរបស់ពួកគេតាមវិធីអន្តរកម្មទៅដល់សិស្សដទៃទៀតនៅក្នុងក្លឹប។ បទបង្ហាញអាចមានរូបភាពជាបណ្ណប្រកាស ការសម្តែងតួ ឬជាគំនិតផ្សេងៗទៀត។ កិច្ចការសំខាន់ក្នុងការកត់ចំណាំទៅលើទីកន្លែងដែលព័ត៌មានអាចត្រូវបានរកឃើញ ឬពេលណាដែលអ្នកត្រូវការវា និងបំពេញបញ្ជីដោយមានឯកសារយោងផងដែរ។

- **ការរៀនតាមរយៈខ្សែភាពយន្ត**

ការមើលខ្សែភាពយន្ត ឬឯកសារដែលពាក់ព័ន្ធនឹងទាក់ទាញការយកចិត្តទុកដាក់របស់សិស្ស។ ខ្សែភាពយន្តត្រូវផ្តោតការយកចិត្តទុកដាក់ទៅលើព្រឹត្តិការណ៍ជាតិដែលពាក់ព័ន្ធ (ឧ. ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ តួអង្គ...) វាក៏ជារឿងសំខាន់ក្នុងការបង្កើតវិធីសាស្ត្ររៀនផ្សេងៗគ្នា ព្រោះប្រទេសចំនួន១០ នឹងត្រូវបានសិក្សា។ ទាំងនេះគឺជាគំនិតខ្លះៗនៃខ្សែភាពយន្ត ឬឯកសារ៖

- សម្រាប់សិង្ហបុរី និងហ្វីលីពីន៖ “**Ilo Ilo**” និពន្ធដោយ Anthony Chen ឆ្នាំ២០១៣។
- សម្រាប់ភូមា ឬមីយ៉ាន់ម៉ា៖ “**The Lady**” និពន្ធដោយ Luc Besson ឆ្នាំ២០១១។ ខ្សែភាពយន្តជីវប្រវត្តិអ្នកស្រី អ៊ុងសាន ស៊ូជី) ឬ “**They call it Myanmar: Lifting the curtains**” និពន្ធដោយ Robert H. Lieberman ឆ្នាំ២០១២ (ភាពយន្តឯកសារ) ឬ “**Kayan Beauties**” និពន្ធដោយ Aung Ko Latt ឆ្នាំ ២០១២។
- សម្រាប់វៀតណាម៖ “**Floating Lives**” និពន្ធដោយ Nguyen Phan Quang Binh ឆ្នាំ២០១០ ឬ “**Good morning Vietnam**” និពន្ធដោយ Barry Levinson ឆ្នាំ១៩៨៧។
- សម្រាប់ឥណ្ឌូណេស៊ី៖ “**Sokola Rimba**” និពន្ធដោយ Riri Riza ឆ្នាំ២០១៣ (សាលារៀនក្នុងព្រៃ)
- សម្រាប់ប្រទេសឡាវ៖ “**The Rocket**” និពន្ធដោយ Kim Mordaunt ឆ្នាំ២០១៣

គំនិតជាច្រើនទៀតពីខ្សែភាពយន្តអាស៊ាន អាចរកបាននៅលើវេបសាយមហោស្រពខ្សែភាពយន្តអាស៊ាន ឆ្នាំ២០១៤ - នៅទីនេះ៖ http://aff.usaseancreativeproject.org/។ ខ្សែភាពយន្តមានជាភាសារបស់ជាតិនីមួយៗ ដោយមានអក្សររត់លើអេក្រង់ជាភាសាអង់គ្លេស។

**សម្គាល់៖** គ្រូត្រូវមើលវីដេអូជាមុនសិន មុននឹងចាក់បញ្ចាំងខ្សែភាពយន្តឱ្យសិស្សមើល។ គ្រូត្រូវចំណាយពេលជ្រើសរើសខ្សែភាពយន្តសមស្រប ព្រោះខ្សែភាពយន្តខ្លះអាចមានអំពើហិង្សា និងមិនសមស្របសម្រាប់សិស្សមួយចំនួន។

➢ **ការអញ្ជើញវាគ្មិន**

សិស្សអាចអញ្ជើញវាគ្មិនមកនិយាយពីប្រទេសរបស់គាត់។ វាគ្មិនជាបុគ្គលណាម្នាក់ដែលមកពីប្រទេសអាស៊ាន ឬបុគ្គលណាម្នាក់ដែលមានចំណេះដឹងពីប្រទេសអាស៊ានណាមួយ (មានចំណេះដឹងល្អពីប្រទេសអាស៊ានពីព្រោះគាត់ធ្លាប់បានទៅរស់នៅ ឬបានធ្វើដំណើរចេញចូលញឹកញាប់ក្នុងប្រទេសនោះ)។ លទ្ធភាពមួយផ្សេងទៀតអាចអញ្ជើញគ្រូមកពីសាកលវិទ្យាល័យវេស្ទើន។ សាកលវិទ្យាល័យវេស្ទើន ទើបតែបើកថ្នាក់បរិញ្ញាបត្រថ្មីមួយហៅថា «ច្បាប់អាស៊ាន»។ វាគួរឱ្យចាប់អារម្មណ៍ក្នុងការជួបជាមួយគ្រូណាម្នាក់ក្នុងចំណោមថ្នាក់សិក្សាដូចតទៅនេះ៖

- ការសិក្សាពីវប្បធម៌អាស៊ាន
- ប្រវត្តិសាស្ត្រអាស៊ាន
- នយោបាយ និងគោលនយោបាយនៅក្នុងអាស៊ាន
- ទំនាក់ទំនងអន្តរជាតិរបស់អាស៊ាន

សូមសាកសួរសាកលវិទ្យាល័យវេស្ទើនកំពង់ចាម ដើម្បីឱ្យប្រាកដថាមានការបើកថ្នាក់បរិញ្ញាបត្រ
http://western.edu.kh/wu/index.php?mm=bachelorlaw

**សម្គាល់៖** សម្រាប់បប្រទេសតូចដូចជា ប្រ៊ុយណេដារូសាឡឹម និងសិង្ហបុរី គឺតម្រូវឱ្យក្រុមសមាជិកក្លឹបណាមួយទទួលខុសត្រូវលើប្រទេសទាំងពីរនេះតែម្តង ដោយសមាជិកក្រុមនោះត្រូវចែកគ្នាជា ២ក្រុម ហើយក្រុមនីមួយៗត្រូវធ្វើការងារលើប្រទេសទាំងពីរម្នាក់មួយ។

### ៤.២.៣. ការតាំងពិព័រណ៍ស្នាដៃក្នុងបណ្ណាល័យ

សកម្មភាពគួរឱ្យចាប់អារម្មណ៍មួយទៀតសម្រាប់ក្លឹបគឺ ការរៀបចំតាំងពិព័រណ៍ពីប្រទេសសមាជិកអាស៊ានដែលធ្វើឱ្យមានចាប់អារម្មណ៍ពីអ្នកដទៃ។ ដូច្នេះពេលបញ្ចប់ការស្រាវជ្រាវនីមួយៗ សិស្សនឹងរៀបចំក្តារខៀនព័ត៌មានពីការស្រាវជ្រាវរបស់ពួកគេ ដើម្បីតាំងពិព័រណ៍ក្នុងបណ្ណាល័យ ឬក្នុងថ្នាក់រៀន។ សកម្មភាពនេះនឹងផ្តល់ឱកាសដល់សិស្សក្នុងការអភិវឌ្ឍបំណិនច្នៃប្រតិដ្ឋ ការរៀបចំ និងបំណិនសរសេររបាយការណ៍សង្ខេប។

ទោះជាយ៉ាងណាក៏ដោយ មានការណែនាំថា សិស្សគួរធ្វើការតាំងពិព័រណ៍ជាក្រុមដើម្បីចំណេញពេលវេលា ពីព្រោះពួកគេនឹងមានកិច្ចការជាច្រើនដែលត្រូវធ្វើក្នុងការតាំងពិព័រណ៍ដូចជា ការគូសរូប ការតុបតែង និងការស្រាវជ្រាវ។ល។ តាមការពិតក្តារខៀនព័ត៌មានគួរតែមានពណ៌ចម្រុះ និងមានការរចនាឱ្យបានល្អដើម្បីទាក់ទាញភ្នែក និងការចាប់អារម្មណ៍របស់សិស្ស។ សិស្សគួរចែករំលែកកិច្ចការ ការទទួលខុសត្រូវ និងធ្វើការ

ងារជាក្រុម។

## ការតាំងពិព័រណ៍ក្នុងបណ្ណាល័យ

- **វត្ថុបំណង៖** ដើម្បីចែករំលែកការស្រាវជ្រាវតាមរយៈការបង្កើតក្ដារខៀនព័ត៌មានគួរឱ្យទាក់ទាញ និងពេញលេញមួយ ដើម្បីអភិវឌ្ឍភាពច្នៃប្រតិដ្ឋ និងការងារជាក្រុមរបស់ពួកគេ។
- **សម្ភារៈ៖** ប៊ិក ហ្វឺត ក្រដាសពណ៌ ក្រដាសផ្ទាំងធំ (poster paper) កុំព្យូទ័រ

បន្ទាប់ពីបានស្រាវជ្រាវពីប្រទេសមួយរួចមក សិស្សអាចចែករំលែកចំណេះដឹងរបស់ពួកគេដោយផលិតក្ដារខៀនព័ត៌មាន (poster board) ដ៏គួរឱ្យទាក់ទាញក្នុងមជ្ឈមណ្ឌលសាលារៀន។ សិស្សគួរមានសេរីភាពក្នុងការច្នៃប្រតិដ្ឋតាមអ្វីដែលពួកគេចង់ធ្វើ។

ជាដំបូង សិស្សត្រូវតែសម្រេចចិត្តពីអ្វីដែលជាព័ត៌មានពាក់ព័ន្ធ ដែលពួកគេចង់ចែករំលែកជាមួយអ្នកដទៃ។ ពួកគេត្រូវធ្វើសេចក្ដីព្រាងមួយ បន្ទាប់មកពេលដែលសេចក្ដីព្រាងនោះបានយល់ព្រមដោយសមាជិកទាំងអស់ សិស្សអាចបង្កើតជាបណ្ណប្រកាសសម្រេចជាស្ថាពរមួយ។

បណ្ណប្រកាសទីមួយ គួរនិយាយពីព័ត៌មានទូទៅពីអាស៊ាន។ ក្រោយមកទៀត សិស្សគួរចាប់ផ្ដើមដោយធ្វើបទបង្ហាញពីកម្ពុជា ហើយបន្ទាប់មកគឺបណ្ដាប្រទេសជិតខាងដូចជា វៀតណាម ថៃ ឡាវ ។ល។

ការណែនាំខ្លះៗសម្រាប់បង្កើតក្ដារខៀនព័ត៌មានរបាយការណ៍ប្រទេសមួយដ៏ស្រស់ស្អាត និងទាក់ទាញ៖

ក្ដារខៀនព័ត៌មាន គួរបង្ហាញតែព័ត៌មានណាដែលពាក់ព័ន្ធតែប៉ុណ្ណោះ។ ក្ដារខៀនព័ត៌មានមិនគួរផ្ទុកព័ត៌មានលើសកំណត់ពេកនោះទេ។ វាជាការប្រសើរ ដែលប្រើប្រាស់ពាក្យគន្លឹះ ឬឃ្លាខ្លីៗ ជាជាងឃ្លា ឬកថាខណ្ឌវែងៗពេក។ សិស្សគួរប្រើប្រាស់រូបគំនូរ ក្រដាសពណ៌ ហ្វឺត រូបភាពបោះពុម្ពចេញពីអ៊ីនធឺណិត... ទិដ្ឋភាពជាក់ស្ដែងនៃក្ដារខៀនព័ត៌មានរបស់គម្រោងមានភាពសំខាន់ជាទីបំផុត។ ដើម្បីឱ្យកាន់តែមានភាពទាក់ទាញពីអ្នកដទៃថែមទៀត សិស្សអាចដាក់បញ្ចូលព័ត៌មានបែបសប្បាយៗពីប្រទេសនោះ។ សិស្សអាចធ្វើបណ្ណប្រកាសដោយមានរូបសណ្ឋាននៃប្រទេសនោះ។ ពួកគេក៏អាចប្រើអក្សរបែបច្នៃប្រតិដ្ឋ និងបង្កើតជាដ្យាក្រាមផងដែរ។

ក្ដារខៀនបង្ហាញព័ត៌មានពីប្រទេស គឺត្រូវស្អាត គ្មានការគូសខ្វែង និងមើលទៅគួរឱ្យទាក់ទាញ។






### ៤.២.៤. ការបង្កើតប្រអប់សំណុំឯកសារ ឬខិត្តប័ណ្ណអាស៊ានក្នុងបណ្ណាល័យ

ការបង្កើតប្រអប់សំណុំឯកសារព័ត៌មានពីអាស៊ាន និងរដ្ឋជាសមាជិក គឺជាសកម្មភាពមួយដើម្បីតាមដានការសិក្សាស្រាវជ្រាវរបស់ក្លឹប។ ប្រអប់សំណុំឯកសារនេះ នឹងត្រូវដាក់ក្នុងបណ្ណាល័យ ដែលអាចប្រើជាឯកសារយោងសម្រាប់ការស្រាវជ្រាវ។

សំណុំប្រអប់ឯកសារ គឺជាវិធីមួយក្នុងការរៀបចំឯកសារព័ត៌មានបែបសាមញ្ញ និងទាក់ទាញ។ ប្រអប់សំណុំឯកសារនេះ នឹងត្រូវបញ្ចូលព័ត៌មានរដ្ឋសមាជិកអាស៊ានទាំងអស់។ សិស្សអាចប្រមូលផ្តុំគំនិតពីការរៀបចំបញ្ចូលព័ត៌មានអាស៊ានដែលគួរឱ្យចាប់អារម្មណ៍សម្រាប់សិស្សដទៃទៀត (ឧ. របបនយោបាយ ប្រព័ន្ធអប់រំ ព្រឹត្តិការណ៍វប្បធម៌ និងប្រពៃណី វិមាន ឬប្រាសាទល្បីៗ សេដ្ឋកិច្ច ការយល់ដឹងពីភូមិសាស្ត្រ ជំនឿសាសនា ក្រុមជនជាតិភាគតិច និងតួនាទីយេនឌ័រ។ល។)

សកម្មភាពនេះនឹងធ្វើឱ្យសិស្សអាចអនុវត្ត និងអភិវឌ្ឍបំណិនសំណេរ និងការច្នៃប្រតិដ្ឋរបស់ពួកគេ ដោយធ្វើសំណុំប្រអប់ឯកសារបទបង្ហាញដែលគួរឱ្យចាប់អារម្មណ៍។

## ការបង្កើតប្រអប់សំណុំឯកសារ ឬខិត្តប័ណ្ណ

- **វត្ថុបំណង៖** ដើម្បីឱ្យសិស្សអភិវឌ្ឍន៍សមត្ថភាពច្នៃប្រតិដ្ឋ និងការសរសេររបស់ពួកគេ។
- **សម្ភារៈ ៖** ក្រដាស ក្រដាសពណ៌ ខ្មៅដៃ និងកុំព្យូទ័រ។

ព័ត៌មានទាំងអស់ដែលបានប្រមូលក្នុងអំឡុងពេលស្រាវជ្រាវ គួរចងក្រងទុកក្នុងប្រអប់សំណុំឯកសារ ឬខិត្តប័ណ្ណដែលរក្សាទុកក្នុងបណ្ណាល័យសម្រាប់គ្រូ និងសិស្សអាចប្រើប្រាស់វាជាឯកសារយោងនាពេលក្រោយៗ។

- **នីតិវិធី៖**

ទាំងនេះ គឺជាជំហានទាំងឡាយដើម្បីជួយសិស្សក្នុងការបង្កើតប្រអប់សំណុំឯកសារធ្វើបទបង្ហាញ។ សិស្សអាចធ្វើតាមប្រព័ន្ធកុំព្យូទ័រ ឬសរសេរដោយដៃ។ កុំព្យូទ័រអាចប្រើប្រាស់បានលុះត្រាណាតែសិស្សមានអារម្មណ៍ថាងាយស្រួលគ្រប់គ្រាន់ជាមួយនឹងជំនាញកុំព្យូទ័រប៉ុណ្ណោះ។ ខ្លឹមសាររបាយការណ៍វែង ឬខ្លី វាអាស្រ័យទៅលើក្លឹបមុខវិជ្ជានោះ ប៉ុន្តែវាគួរតែមានក្របមុខដ៏ស្រស់ស្អាត តារាងមាតិកា សេចក្តីផ្តើម ជំពូក (ព័ត៌មានទូទៅពីអាស៊ាន និងលក្ខណៈរបស់ប្រទេសនីមួយៗ) សេចក្តីសន្និដ្ឋាន បញ្ជីឯកសារយោង និងធនធានទាំងឡាយដែលបានប្រើប្រាស់។ ប្រអប់សំណុំឯកសារ នឹងផ្ទុកដោយផែនទី ទង់ជាតិ សំណោរចម្រុះពណ៌។ល។ ដើម្បីធ្វើឱ្យមានភាពទាក់ទាញក្នុងការអានសម្រាប់សិស្សដទៃ។

**ជំហានទី១៖** សិស្សមើលប្រអប់សំណុំឯកសារដែលមានភាពខុសៗគ្នាក្នុងបណ្ណាល័យ ដើម្បីបានគំនិតផ្សេងៗ។

**ជំហានទី២៖** សិស្សរួមគ្នាសម្រេចចិត្តពីរបៀបដែលពួកគេចង់ធ្វើឱ្យប្រអប់សំណុំឯកសាររបស់ពួកគេមើលទៅមានលក្ខណៈបែបណាមួយ។ សិស្សគួរធ្វើផែនការ និងសម្រេចចិត្តលើជំពូកនានា មានរបៀបសរសេរខុសៗគ្នា ដែលអាចប្រើប្រាស់បានដោយសិស្សក្នុងការធ្វើបទបង្ហាញពីរដ្ឋសមាជិកអាស៊ាន។ សិស្សអាចប្រើប្រាស់បំណិនក្នុងការសរសេរបែបផ្លូវការ និងក្រៅផ្លូវការ។ សំណេរផ្លូវការ នឹងមានរូបភាពជាអត្ថបទបន្តបន្ទាប់

គ្នា ដែលប្រាប់ពីអាស៊ាន ឬរដ្ឋសមាជិក។ ព័ត៌មានពីប្រទេសណាមួយ អាចចងក្រងទុកជាបណ្ណប្រទេស (សន្លឹកព័ត៌មាន) ឬសាច់រឿងប្រាប់ពីប្រទេស (ដូចជាអត្ថបទមួយ) ឬដោយធ្វើរបាយការណ៍សម្ភាសន៍។ ប្រអប់សំណុំឯកសារអាចមានគំរូរួមមួយ ឬរដ្ឋសមាជិកអាស៊ានអាចត្រូវបានអភិវឌ្ឍន៍ខុសៗគ្នាទៅតាមបំណងប្រាថ្នារបស់សិស្ស។

**ជំហានទី៣៖** ប្រមូលព័ត៌មានទាំងអស់ដែលបានរកឃើញពីការស្រាវជ្រាវពីដំបូង ហើយព័ត៌មានបន្ថែមនោះអាចរកឃើញតាមតម្រូវការ។

**ជំហានទី៤៖** ពេលសរសេរព័ត៌មានដំបូង គឺសរសេរជាពង្រាងដែលមិនទាន់គិតពីកំហុសដែលមានទាំងឡាយ បន្ទាប់មកគឺធ្វើកំណែសម្រេចចុងក្រោយ ដែលសរសេរយ៉ាងមានរបៀប មានគម្លាតរវាងរូបភាព ឬគំនូរ។ សិស្សគួរធ្វើឱ្យប្រាកដថា នៅពេលចម្លងពាក្យពេចន៍ចេញពីសៀវភៅ ឬវេបសាយណាមួយត្រូវមានកំណត់សម្គាល់ (foot note) នៅខាងក្រោមនៃរបាយការណ៍នោះ។

**ជំហានទី៥៖** នៅពេលដែលបញ្ចប់មាតិការួចរាល់ បន្ទាប់មកត្រូវសរសេរសេចក្ដីផ្ដើមដោយពន្យល់ខ្លីៗថាតើឯកសារនោះចង់និយាយពីអ្វី។

**ជំហានទី៦៖** នៅចុងបញ្ចប់នៃរបាយការណ៍ត្រូវភ្ជាប់ជាមួយឯកសារយោងនានា។ នេះគឺជាបញ្ជីមួយដែលរាយឈ្មោះពីប្រភពនានា វេសាយ សៀវភៅ និងបទសម្ភាសន៍ ដែលបានប្រើប្រាស់។

**ជំហានទី៧៖** នៅពេលរបាយការណ៍ជិតបញ្ចប់ គួររៀបចំក្របស្រស់ស្អាតមួយដែលមានចំណងជើងនៃរបាយការណ៍ ឈ្មោះអ្នកនិពន្ធ និងការតុបតែងឱ្យបានល្អ។

ឧទាហរណ៍៖

   

**ក្របមុខ** **តារាងមាតិកា** **ជំពូក** **បញ្ជីមានឯកសារយោង**

### ៤.២.៩. ការពិភាក្សា និងការជជែកដេញដោល

ការអានឯកសារផ្លូវការរបស់អាស៊ាន អាចមានភាពលំបាកសម្រាប់សិស្ស ប៉ុន្តែឯកសារទាំងនេះជួយសិស្សក្នុងការអភិវឌ្ឍបំណិនត្រិះរិះពិចារណា។ សិស្សអាចងាយយល់ពីប្រភេទឯកសារទាំងនេះ ដោយមានការគាំទ្រពីគ្រូ។ សិស្សអាចរៀនឆ្លុះបញ្ចាំងលើសហគមន៍អាស៊ានដោយផ្អែកលើការអានឯកសារផ្លូវការនេះ។ សំណួរបន្ថែមពីអាស៊ាន ក៏អាចពិភាក្សាគ្នាដើម្បីអភិវឌ្ឍការត្រិះរិះពិចារណារបស់សិស្សផងដែរ។ សកម្មភាពនេះធ្វើឡើងជាមួយសិស្សពេញវ័យ ដែលអាចស្វែងយល់ពីសហគមន៍អាស៊ាន។

# ការពិភាក្សា និងការជជែកដេញដោល

- **វត្ថុបំណង៖** សិស្សយល់ពីបញ្ហាដែលកើតមានក្នុងរដ្ឋសមាជិកអាស៊ាន និងកម្ពុជាលើទស្សនវិស័យទាក់ទងនឹងសេដ្ឋកិច្ច នយោបាយ និងសង្គម។ សិស្សនឹងរៀនពីការរៀបចំគំនិត និងការជជែកដេញដោល។

ផ្អែកលើចំណេះដឹងសិស្ស និងឯកសារផ្លូវការ សំណួរទាំងឡាយខាងក្រោមនេះ អាចពិភាក្សាជាមួយគ្រូដូចខាងក្រោម៖

- តើរដ្ឋសមាជិកអាស៊ានមានលក្ខណៈវប្បធម៌ និងភូមិសាស្ត្រអ្វីខ្លះដែលដូចគ្នា?
- តើបណ្តាប្រទេសទាំងនោះកាន់តែរឹងមាំដូចម្តេចខ្លះ នៅពេលពួកគេភ្ជាប់ទំនាក់ទំនងជាមួយគ្នា?
- តើរដ្ឋសមាជិកអាស៊ានអាចសម្រេចអ្វីរួមគ្នាបានខ្លះ? ហើយអ្វីខ្លះដែលពួកគេមិនអាចសម្រេចបាន ប្រសិនបើពួកគេស្ថិតនៅក្នុងនាមជាប្រជាជាតិដាច់ដោយឡែកពីគ្នា?
- តើមានមធ្យោបាយអ្វីខ្លះ ដែលមនុស្សអាចភ្ជាប់ទំនាក់ទំនងជាមួយគ្នាបាន?
- តើការចូលជាផ្នែកមួយនៃសហគមន៍អាស៊ានមានន័យដូចម្តេច?
- តើមានគុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះសម្រាប់ប្រទេសកម្ពុជា?

ប្រធានបទផ្សេងៗទៀតអាចពិភាក្សាបានដូចជា អន្តោប្រវេសន៍អាស៊ាន បរិស្ថាន ការភ្ជាប់ទំនាក់ទំនងសាកលលោក និងតំបន់ ការប្រារព្ធប្រពៃណី ការគោរពអត្តសញ្ញាណ និងភាពចម្រុះគ្នា។

សិស្សអាចចំណាយពេលអានឯកសារពាក់ព័ន្ធ និងពិភាក្សាជាមួយគ្រូ។ យោងតាមឯកសារទាំងនោះ សិស្សអាចផ្តល់ទស្សនៈផ្ទាល់ខ្លួនលើប្រធានបទផ្សេងៗគ្នា។ ពួកគេអាចប្រៀបធៀបឯកសារច្បាប់ដើម និងជំហរបច្ចុប្បន្នរបស់កម្ពុជា។ ឧទាហរណ៍៖

- តើកម្ពុជាគោរពតាមមាត្រាទាំងអស់ក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលចុះហត្ថលេខាដោយបណ្តាប្រទេសអាស៊ានដែរឬទេ?
- សមាហរណកម្មអាស៊ានឆ្នាំ២០១៥ តើកម្ពុជាបានត្រៀមខ្លួនរួចហើយឬនៅ?

## ឯកសារដែលត្រូវអាន និងពិភាក្សា៖

- ចរនាសម្ព័ន្ធអាស៊ាន
http://www.asean.org/archive/publications/ASEAN-Charter.pdf
- សហគមន៍សេដ្ឋកិច្ចអាស៊ាន
http://www.asean.org/archive/5187-10.pdf
- អាស៊ាន និងសិទ្ធិកុមារ
http://childrightscoalitionasia.org/asean-and-child-rights/
- សេចក្តីថ្លែងការណ៍ទីក្រុងហាណូយស្តីពីការពង្រឹងសុខុមាលភាព និងការអភិវឌ្ឍស្ត្រី និងកុមារអាស៊ាន
http://www.asean.org/news/item/ha-noi-declaration-on-the-enhancement-of-welfare-and-development-of-asean-women-and-children
- «អាស៊ានឆ្នាំ២០៣០៖ ការរីកចម្រើនទាំងអស់គ្នាដើម្បីវិបុលភាពសេដ្ឋកិច្ច និងបញ្ហាប្រឈម» ខែមករា

ឆ្នាំ២០១៤ http://www.cdri.org.kh/webdata/download/wp/wp90e.pdf



### ៤.២.៦. ទស្សនកិច្ច

ការដឹកនាំសិស្ស ធ្វើទស្សនកិច្ចសិក្សារយៈពេលខ្លីនៅកន្លែងណាមួយដែលគួរឱ្យចាប់អារម្មណ៍ គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពរីករាយជាច្រើនដែលក្លឹបអាចធ្វើបាន។ គ្រូដឹកនាំក្លឹប គួរធ្វើគម្រោងផែនការសកម្មភាពជាមួយសមាជិកក្លឹប។ មុនពេលឱ្យសិស្សធ្វើទស្សនកិច្ចសិក្សានៅកន្លែងណាមួយ គ្រូគួរសុំការអនុញ្ញាតពីឪពុកម្តាយរបស់សិស្សដើម្បីឱ្យពួកគាត់បានដឹងច្បាស់ជាមុនសិន។ ខាងក្រោមនេះ គឺជាបញ្ជីសកម្មភាពដែលអាចរៀនបានពីអាស៊ាន៖

- ទស្សនាការិយាល័យលេខាធិការដ្ឋានអាស៊ាននៅភ្នំពេញ ប្រទេសកម្ពុជា
- ទស្សនាកន្លែងប្រមូលផ្តុំជនជាតិជាច្រើនមកពីបណ្តាប្រទេសអាស៊ានដែលនៅជិតខាងដូចជា ថៃ ឡាវ ឬវៀតណាម។ អ្នកអាចឈប់នៅភោជនីយដ្ឋាន ឬប្រាសាទ ដើម្បីស្វែងយល់បន្ថែមពីវប្បធម៌របស់ប្រទេសណាមួយ។ គួរកត់ចំណាំនូវនិមិត្តសញ្ញាណាមួយដែលអ្នកបានមើលឃើញក្នុងភាសានៃប្រទេសជាសមាជិកអាស៊ាន។
- ទស្សនាវេទិកាថ្នាក់ជាតិអាស៊ាន ប្រសិនបើមានព្រឹត្តិការណ៍ណាមួយកើតឡើងក្នុងប្រទេសរបស់អ្នក។ ប្រទេសកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះកិច្ចប្រជុំថ្នាក់តំបន់នៅឆ្នាំ២០២២។

### ៤.២.៧. ការប្រជុំឆ្លុះបញ្ចាំងដើម្បីវាយតម្លៃសកម្មភាពប្រចាំឆ្នាំ

ការប្រជុំនេះ អាចមានលក្ខណៈជាការធ្វើទស្សនកិច្ចសិក្សា ដើម្បីឆ្លុះបញ្ចាំងក្នុងបរិយាកាសស្ងប់ស្ងាត់មួយពីអ្វីដែលបានកើតឡើងក្នុងក្លឹបអំឡុងរយៈពេលមួយឆ្នាំ។ សិស្សអាចចំណាយពេលវេលាពិភាក្សាគ្នាពីសកម្មភាពដែលពួកគេពេញចិត្តនៅក្នុងឆ្នាំនោះ។ គ្រូដឹកនាំក្លឹប អាចឆ្លៀតឱកាសចងក្រងឯកសារវាយតម្លៃខ្លីមួយលើចំណុចកែលម្អសម្រាប់ឆ្នាំបន្ទាប់។

## ឧបសម្ព័ន្ធទី១៖ ការវាយតម្លៃចំណាប់អារម្មណ៍សិស្ស

### សេចក្តីផ្តើម

ការចូលរួមក្លឹប គឺអាស្រ័យលើការសម្រេចចិត្តរបស់សិស្សផ្ទាល់។ ការវាយតម្លៃចំណាប់អារម្មណ៍សិស្សពីការចូលរួមក្លឹបនេះ គ្រូត្រូវពន្យល់ណែនាំពីអត្ថន័យក្លឹបនោះជាមុនសិន។ ការណែនាំនេះអាចនិយាយផ្ទាល់មាត់ទៅកាន់សិស្សក្នុងថ្នាក់ ឬអាចសរសេរបិទនៅទីធ្លាបរិវេណសាលា ឬយើងអាចប្រើវិធីទាំងពីរនេះតែម្តង។ សេចក្តីណែនាំទាំងអស់រួមមានចំណុចដូចខាងក្រោមនេះ៖

- **វត្ថុបំណង៖** ដើម្បីបង្កើនការយល់ដឹងរបស់សិស្សពីអង្គការអន្តររដ្ឋាភិបាលក្នុងតំបន់ និងបណ្តាប្រទេសជាសមាជិក។
- **សកម្មភាព៖** ការស្រាវជ្រាវជាក្រុមតាមរយៈប្រព័ន្ធកុំព្យូទ័រ សៀវភៅ ការធ្វើបទសម្ភាសន៍ ការតាំងពិព័រណ៍ជារៀងរាល់ខែពីប្រទេសអាស៊ាន និងការបង្កើតប្រអប់សំណុំឯកសារបទបង្ហាញរាល់ការធ្វើទស្សនកិច្ចសិក្សា។
- **ការវាយតម្លៃ៖** ពុំមានការវាយតម្លៃ ឬដាក់ពិន្ទុជាលក្ខណៈផ្លូវការទេ គឺសិស្សចូលរួមក្នុងសកម្មភាពក្លឹបដោយការពេញចិត្តរបស់ពួកគេ ពុំមែនដោយសារការបង្ខំឡើយ។
- **ការចូលរួម៖** សមាជិកភាពក្លឹបចូលរួមដោយស្ម័គ្រចិត្ត។
- **ការប្រជុំ៖** ការប្រជុំសាមញ្ញ (ប្រហែល២សប្តាហ៍ម្តង) ដើម្បីពិភាក្សាពីសកម្មភាពដែលបានគ្រោងទុក។ ចំណុចខាងលើនេះ ត្រូវអនុវត្តក្រៅម៉ោងសិក្សា ឬថ្ងៃឈប់សម្រាក។

### កម្រងសំណួរ

សូមបង្ហាញពីកម្រិតចាប់អារម្មណ៍របស់អ្នកពីការចូលរួមក្នុងក្លឹបប្រវត្តិសាស្ត្រ ដោយរើសយកប្រអប់តែមួយក្នុងចំណោមប្រអប់ទាំង ៣ ខាងក្រោមនេះ៖

- ☐ ខ្ញុំគ្មានចំណាប់អារម្មណ៍សោះក្នុងការចូលរួមក្នុងក្លឹបអាស៊ាននេះ។
- ☐ ខ្ញុំចាប់អារម្មណ៍ក្នុងការចូលរួមក្លឹបនេះ ប៉ុន្តែខ្ញុំមិនដឹងច្បាស់ថាតើខ្ញុំមានពេលចូលរួមដែរ ឬទេ។
- ☐ ខ្ញុំចាប់អារម្មណ៍ក្នុងការចូលរួមក្លឹបនេះណាស់ ហើយខ្ញុំដឹងច្បាស់ថាខ្ញុំមានពេលដើម្បីចូលរួមក្លឹបនេះ។

## ឧបសម្ព័ន្ធទី២៖ ការបែងចែកភារកិច្ច

### ១. ប្រធាន

- រៀបចំការប្រជុំក្លឹប
- សម្របសម្រួលការរៀបចំរបៀបវារៈកិច្ចប្រជុំនីមួយៗ
- សម្របសម្រួលការប្រជុំ
- សម្របសម្រួលជាមួយនាយកសាលាដើម្បីធានាថាមានកន្លែងសម្រាប់ប្រជុំ
- បង្កើតសម្ព័ន្ធភាពរវាងក្លឹប និងគណៈកម្មការគ្រប់គ្រងសាលា
- ត្រួតពិនិត្យការអនុវត្តផែនការប្រចាំត្រីមាស
- រាយការណ៍ពីបញ្ហាទាំងឡាយដែលកើតឡើងដល់គ្រូដឹកនាំក្លឹប

### ២. អនុប្រធាន

- បំពេញតួនាទីជាប្រធានអង្គប្រជុំនៅពេលដែលប្រធានអវត្តមាន
- ជួយសម្របសម្រួលកិច្ចប្រជុំ
- កត់ត្រាកំណត់ហេតុ

### ៣. ហេរញ្ញិក

- ទទួលខុសត្រូវលើថវិកាដែលគ្រូដឹកនាំបានផ្តល់ឱ្យសម្រាប់ធ្វើសកម្មភាពផ្សេងៗ រួមមានការទិញសម្ភារៈសម្រាប់ការតាំងពិព័រណ៍ និងការធ្វើដំណើរទស្សនកិច្ចសិក្សា។ល។
- ថែរក្សាកំណត់ត្រាថវិកាទាំងអស់ដែលទទួលបានពីគ្រូដឹកនាំក្លឹប
- ទិញ ឬចំណាយតាមការបង្ហាញរបស់គ្រូដឹកនាំក្លឹប

### ៤. ប្រធានក្រុម

- ណែនាំពីការដឹកនាំក្រុម
- ធ្វើរបាយការណ៍តំណាងក្រុមជូនដល់ប្រធានអង្គប្រជុំ ឬគ្រូដឹកនាំក្លឹប
- ផ្សព្វផ្សាយព័ត៌មានដែលទទួលបានពីប្រធានអង្គប្រជុំ ឬ គ្រូដឹកនាំក្លឹបដល់សមាជិកក្នុងក្រុម

### ៥. គ្រូដឹកនាំក្លឹប

- ផ្តល់ការណែនាំដល់ក្លឹបក្នុងការបង្កើតផែនការ រៀបចំការប្រជុំជ្រើសរើសប្រធានក្លឹបដើម្បីឱ្យគាត់
- អាចធ្វើការងារផ្សេងៗបានដោយខ្លួនឯង។
- ជួយផ្នែកបច្ចេកទេសទាក់ទងនឹងក្លឹបប្រវត្តិសាស្ត្រ (មេរៀនស្តីពីអក្សរបុរាណ  យុគសម័យប្រវត្តិសាស្ត្រនៅក្នុងប្រទេសកម្ពុជា។ល។
- តំណាងក្លឹបចំពោះមុខគណៈកម្មការនៅពេលធ្វើប្រតិបត្តិការថវិកា។
- សម្របសម្រួលសកម្មភាពផ្សេងៗដូចជា ការរៀបចំផែនការ និងការធ្វើដំណើរទស្សនកិច្ចសិក្សា។
- សម្របសម្រួលផ្នែកទំនាក់ទំនងរវាងក្លឹប និងរដ្ឋបាលរបស់សាលានៅពេលមានសកម្មភាពផ្សេងៗដូចជា ការប្រើប្រាស់បណ្ណាល័យសម្រាប់ប្រជុំជាដើម។
- ត្រួតពិនិត្យធនធានថវិកាដែលក្លឹបប្រើប្រាស់។

## ឧបសម្ព័ន្ធទី៣៖ ការកំណត់ផែនការ

### ត្រីមាសទី១

| សកម្មភាព | វិច្ឆិកា | | | | ធ្នូ | | | | មករា | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| ១. | | | | | | | | | | | | |
| ២. | | | | | | | | | | | | |
| ៣. | | | | | | | | | | | | |
| ៤. | | | | | | | | | | | | |
| ៥. | | | | | | | | | | | | |
| ៦. | | | | | | | | | | | | |
| ៧. | | | | | | | | | | | | |
| ៨. | | | | | | | | | | | | |
| ៩. | | | | | | | | | | | | |
| ១០. | | | | | | | | | | | | |
| ១១. | | | | | | | | | | | | |
| ១២. | | | | | | | | | | | | |

### ត្រីមាសទី២

| សកម្មភាព | កុម្ភៈ | | | | មីនា | | | | មេសា | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| ១. | | | | | | | | | | | | |
| ២. | | | | | | | | | | | | |
| ៣. | | | | | | | | | | | | |
| ៤. | | | | | | | | | | | | |
| ៥. | | | | | | | | | | | | |
| ៦. | | | | | | | | | | | | |
| ៧. | | | | | | | | | | | | |
| ៨. | | | | | | | | | | | | |
| ៩. | | | | | | | | | | | | |
| ១០. | | | | | | | | | | | | |
| ១១. | | | | | | | | | | | | |
| ១២. | | | | | | | | | | | | |

## ឧបសម្ព័ន្ធទី៤៖ ការកំណត់ធនធាន

| ចំណាយ | រូបមន្ត (បរិមាណ x តម្លៃ/ឯកតា) | ទឹកប្រាក់ |
|---|---|---|
| ១. ក្រដាសផ្ទាំងធំ | ១គក្រ x ២ដុល្លារ/គក្រ | ២,០០ដុល្លារ |
| ២. ហ្វឺត | ២ប្រអប់ x ២,៥០ដុល្លារ/ប្រអប់ | ៥,០០ដុល្លារ |
| ៣. ក្រដាសពណ៌ | ២រ៉ាម x ៤ដុល្លារ/រ៉ាម | ៨,០០ដុល្លារ |
| ៤. កម្មសិក្សា<br>អាហារថ្ងៃត្រង់៖<br>រថយន្តឈ្នួល៖ | ១៥នាក់ x ១ដុល្លារ/ម្នាក់<br>៣៥ដុល្លារ/ថ្ងៃ x ១ថ្ងៃ | ១៥ដុល្លារ<br>៣៥ដុល្លារ |
| ៦. សម្ភារៈការិយាល័យទូទៅ | | ៤៨,០០ដុល្លារ |
| **សរុប** | | **១១៣ដុល្លារ** |